តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# សេចក្តីប្រកាសព័ត៌មាន

## ដំណើរការបើកការបោះឆ្នោតបានប្រព្រឹត្តិទៅដោយរលូនទៅតាមបទបញ្ញានិងនិតិវិធី របស់គ.ជ.ប

ភ្នំពេញ, ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ (១០ ព្រឹក)

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧, អង្គការតម្លាភាពកម្ពុជាបានដាក់ពង្រាយអ្នកសង្កេតការណ៍ ១,០៥១នាក់ ដែលបានទទួល ការបណ្តុះបណ្តាល និងមិនប្រកាន់និន្នាការនយោបាយ។ ការដាក់ពង្រាយនេះរួមបញ្ចូលទាំងអ្នកគ្រប់គ្រង ចំនួន ៣៥នាក់ អ្នកសង្កេតការណ៍ចំនួន ៨២២នាក់ ទៅតាមការិយាល័យបោះឆ្នោតចំនួន ៥១១ការិយាល័យទូទាំង ២៥ខេត្ត **ក្រុង និងរាជធានី** ដែល ជាតំណាងនៃសំណាកដែលត្រូវបានជ្រើសរើស តាមវិធីសាស្ត្រស្ថិតិសម្រាប់ ការសង្កេតការណ៍តាម សំណាកគំរូវិទ្យាសាស្ត្រស្ថិតិ (Sample Based Observation—SBO)។ អ្នកសង្កេតការណ៍ចំនួន ២០០នាក់ទៀត ត្រូវបានដាក់ពង្រាយដើម្បីសង្កេតការណ៍នៅការិយាល័យបោះឆ្នោតចំនួន ១០០ការិយាល័យ ក្នុងឃុំ សង្កាត់ចំនួនបីនៅក្នុង រាជធានីភ្នំពេញ, ខេត្តស្វាយរៀង និងខេត្តសៀមរាប។ ការសង្កេតការណ៍តាម សំណាកគំរូវិទ្យាសាស្ត្រស្ថិតិគឺ ជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធភាព ហើយត្រូវបានគេប្រើនៅទូទាំងពិភពលោក សម្រាប់ធ្វើការវាយតម្លៃលើដំណើរការបោះឆ្នោត ដោយឈរលើស្ថិតិ ដែលអនុញ្ញាតិឱ្យអ្នកសង្កេតការណ៍ បោះឆ្នោត បង្ហាញពីការវាយតម្លៃមួយដែលមានភាពត្រឹមត្រូវ និងពេញលេញទៅលើដំណើរការ ថ្ងៃបោះឆ្នោត។

ជារួម គិតមកដល់ម៉ោង ១០ ព្រឹក ការិយាល័យបោះឆ្នោតដែលត្រូវបានសង្កេតការណ៍ស្ទើរទាំងអស់បានបើកដំណើរការទាន់ពេលវេលាដែលបានកំណត់ទុក ហើយមានសម្ភារៈដែលចាំបាច់ទាំងអស់ មានវត្តមានមន្ត្រីការិយាល័យបោះឆ្នោត។ ដូច្នេះ អង្គការតម្លាភាពកម្ពុជាអាចរាយការណ៍បានគិតត្រឹមម៉ោងនេះថា ដំណើរការនៃការរៀបចំ និងការបើកការបោះឆ្នោតបានប្រព្រឹត្តទៅដោយសុចរិត។

## សេចក្តីសង្ខេបនៃការរៀបចំការិយាល័យបោះឆ្នោត និងការបើកដំណើរការបោះឆ្នោត

តាមរយៈរបាយការណ៍ទទួលបានពី ១០០% នៃការិយាល័យបោះឆ្នោតដែលស្ថិតក្នុងការសង្កេតការណ៍តាមសំណាកគំរូវិទ្យាសាស្ត្រស្ថិតិរបស់អង្គការតម្លាភាពកម្ពុជា អង្គការតម្លាភាពកម្ពុជា សូមបង្ហាញរបាយការណ៍នៃការរកឃើញជាបឋម របស់ខ្លួនជាសង្ខេបដូចខាងក្រោម៖

- ៨៨% នៃការិយាល័យបោះឆ្នោតបានបើកទាន់ពេលវេលា។
- ៩៥% នៃការិយាល័យបោះឆ្នោតមានមន្ត្រីការិយាល័យបោះឆ្នោតចំនួន ៦ ។
- នៅពេលបើកការបោះឆ្នោត, ៩៩.៨ % នៃការិយាល័យបោះឆ្នោតមានវត្តមានភ្នាក់ងារគណបក្សនយោបាយ រួមមាន ៩៤% ដែលជាភ្នាក់ងារមកពី គណបក្សប្រជាជនកម្ពុជា និង ៩៤%ភ្នាក់ងារមកពី គណបក្សសង្គ្រោះជាតិ និង ៤៦% ជាភ្នាក់ងារមកពី គណបក្សផ្សេងទៀត ។
- ៨៨%នៃការិយាល័យបោះឆ្នោតមានវត្តមានអ្នកសង្កេតការណ៍មកពីអង្គការផ្សេងទៀតនៅកំឡុងពេលរៀបចំការបោះឆ្នោត និងពេលបើកការបោះឆ្នោត។
- ៩៨% សម្ភារៈសំខាន់ៗទាំងអស់មានវត្តមាននៅក្នុងពេលបើកការិយាល័យបោះឆ្នោត។

- ៩៩.៨ % នៃការិយាល័យបោះឆ្នោត បានបង្ហាញពីប្រអប់សន្លឹកឆ្នោតទទេ ការបិទគម្រប ហិបឆ្នោតដោយចាក់សោរឃ្លុំ និងដាក់នៅកន្លែងដែលអាចមើលឃើញជា សាធារណៈមុនពេលចាប់ផ្តើមនៃការបោះឆ្នោត។
- ៩៥ % នៃការិយាល័យបោះឆ្នោត គ្មានវត្ថុមានសម្ភារៈយុទ្ធនាការឃោសនា ក្នុងចម្ងាយ ១00 ម៉ែត្រនៅខាងក្រៅ ការិយាល័យបោះឆ្នោត។
- ៥៩% នៃការិយាល័យបោះឆ្នោតគ្មានជំរាលសម្រាប់ជនពិការ ជិះរទេះចេញចូល

<u>សម្រាប់ការធ្វើបទសម្ភាសន៍សូមទំនាក់ទំនង៖</u>

លោក **ព្រាប កុល** នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា ទូរស័ព្ទលេខ ០១២ ៨៧៧ ៨៣៣ ឬតាមរយៈអ៊ីម៉ែល kolpreap@ticambodia.org

###

អង្គការតម្លាភាពអន្តរជាតិជាអង្គការសង្គមស៊ីវិលដែលឈានមុខគេក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងលើកម្ពស់សុចរិតភាព សម្រាប់ព័ត៌មានបន្ថែមពីឯកសារយោងនៃប្រភេទទិន្នន័យទាំង១៣ ក៏ដូចជាប្រភេទនៃអ្នក ឆ្លើយតប និងកម្រងសំនួរ សូមចូលទៅកាន់ www.ticambodia.org/sbo2017។

Phnom Penh, 4 June 2017

# PRESS RELEASE

**Opening of the Polling Stations went Smoothly and In Compliance with NEC Rules and Regulations**

**Phnom Penh, 4 June 2017** – On June 4, TI Cambodia deployed 1,051 trained and accredited non-partisan citizen observers. This includes 35 supervisors; 822 observers deployed to a random, representative sample of 411 sample polling stations in all 25 provinces to carry out a sample-based observation (SBO); and 200 observers at all 100 of the polling stations in three communes in Phnom Penh, Svay Rieng and Siem Reap provinces. SBO is an advanced election observation methodology, used worldwide, that draws on proven statistics to allow election observers to present an accurate and comprehensive assessment of the election day process.

Overall, as of 10 a.m., nearly all observed polling stations opened on time, with all the necessary critical materials, and Polling Station Committee (PSC) members present. Thus, TI Cambodia reports that the integrity of the set-up and opening processes has been maintained thus far.

**Summary of Polling Station Set-up and Opening Processes**

With reports received from 100% of TI Cambodia's sampled polling stations, TI Cambodia has summarized its preliminary findings below.

By 7 a.m., 100% of TI Cambodia's observers reported that they were permitted to enter the polling station.

- 88% of polling stations opened on time.
- 95% of polling stations had 6 PSC members present.
- At the time of opening, 99.8% of polling stations had representatives from the political parties' present. Among polling stations where party agents were present, 94% had CPP party agents present, and 94% had CNRP party agents present, and 46% of polling stations had other political party agents present.
- 88% of polling stations had other CSO observers present during setup and opening.
- 98% had all critical materials present at the time of the polling station opening.
- In 99.8% of polling stations the ballot box was shown to be empty, sealed, and placed in public view before the start of voting.
- 95% of polling stations did not have campaign materials present within 100 meters outside of the polling station.
- 59% of polling stations were not accessible to people with wheelchairs.

For further information related to Sample Based Observation, please refer to www.ticambodia.org/sbo2017.

**Media Contacts**

**Mr Preap Kol, Executive Director, (+855) 012 877 833, kolpreap@ticambodia.org**

###

*Transparency International is the civil society organisation leading the fight against corruption*